អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

[D381/12]

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៦១)

**<u>អង្គបុរេជំនុំជម្រះ</u>**

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម នុ័យ ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 09 / 2019
ម៉ោង (Time/Heure): 09:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឲ្យផ្តល់នូវការ បកប្រែដោយត្រឹមត្រូវជាភាសាអង់គ្លេស នូវដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះ យឹម ទិត្យ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ**

---

**<u>សហព្រះរាជអាជ្ញា:</u>**

ជា លាង
Brenda J. HOLLIS

**<u>សហមេធាវីការពារក្តី យឹម ទិត្យ:</u>**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

---

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់ យឹម ទិត្យ សុំឱ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ ឱ្យផ្តល់នូវការបកប្រែជាភាសាអង់គ្លេស នៃដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិដែលត្រឹមត្រូវ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ("សំណើសុំផ្អាក") [1]។

1. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ ("ដីកាសម្រេចលើកលែងការចោទប្រកាន់")[2] តែជាភាសាខ្មែរ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយរបស់គាត់[3] តែជាភាសាអង់គ្លេស។

2. នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ សហមេធាវីការពារក្តី យឹម ទិត្យ បានដាក់ "សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃកាលបរិច្ឆេទ សម្រាប់ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ"[4] ហើយនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ការិយាល័យសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួន[5]។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញដីកាសម្រេចអនុញ្ញាតតាមសំណើនេះ ហើយបង្គាប់ដល់ភាគីនានាឱ្យដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍

---

[1] សំណុំរឿង០០៤/០៧-០៩-២០០៩-អវតក/កសចស("សំណុំរឿង ០០៤") សំណើរបស់ យឹម ទិត្យ សុំឱ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ ឱ្យផ្តល់នូវការបកប្រែជាភាសាអង់គ្លេស នៃដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិដែលត្រឹមត្រូវ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/5 និងឯកសារ D382/5 ("សំណើសុំផ្អាក")។

[2] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។

[3] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

[4] សំណុំរឿង ០០៤ សំណើរបស់ យឹម ទិត្យ សុំពន្យារពេលនៃកាលបរិច្ឆេទ សម្រាប់ការជូនដំណឹងអំពី ការប្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/1 និងឯកសារ D382/1។

[5] សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ យឹម ទិត្យ សុំពន្យាពេលកាលបរិច្ឆេទកំណត់ សម្រាប់សេចក្តីជូនដំណឹងអំពី បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ D381 & D382 (D381 & D382) ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/2 និងឯកសារ D382/2។

ប្រឆាំងដីកាដំណោះស្រាយ ក្នុងសំណុំរឿង០០៤ ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងអំពីការបកប្រែដីកាដំណោះស្រាយទាំងពីរ[6]។

3. នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ"[7] ហើយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ សហមេធាវីការពារក្តី យឹម ទិត្យ បានដាក់ "ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"[8]។ សហព្រះរាជអាជ្ញាជាតិបានដាក់ "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤"[9] នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ បន្ទាប់ពីមានការជូនដំណឹងរបស់គាត់[10] ដែលបានដាក់នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។

4. ឯកសារបកប្រែជាភាសាខ្មែរ សម្រាប់ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានដាក់នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ហើយបានជូនដំណឹងដល់ភាគី នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩។ ឯកសារបកប្រែជាភាសាអង់គ្លេស សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ត្រូវបានដាក់ និងជូនដំណឹង នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩។

---

[6] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពន្យាកាលបរិច្ឆេទសម្រាប់ ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/3 និងឯកសារ D382/3។

[7] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/4។

[8] សំណុំរឿង ០០៤ ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D381/7។ សំណុំរឿង ០០៤ ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D382/9។

[9] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D382/4/1។

[10] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់ សហព្រះរាជអាជ្ញាជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៩ ឯកសារ D382/4។

5. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ការិយាល័យសហព្រះរាជអាជ្ញា បានជូនដំណឹងដល់អង្គបុរេជំនុំជម្រះ តាមរយៈសារអេឡិចត្រូនិកថា ក.ស.ព បានស្នើដល់អង្គភាពបកប្រែភាសាឱ្យត្រួតពិនិត្យមើលឡើងវិញ និងដាក់ម្តងទៀតនូវឯកសារដែលបានកែតម្រូវ សម្រាប់ឯកសារបកប្រែជាភាសាអង់គ្លេស របស់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ[11]។

6. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ សហមេធាវីការពារក្តី យឹម ទិត្យ បានដាក់សំណើសុំផ្អាក ដោយស្នើដល់អង្គបុរេជំនុំជម្រះឱ្យ (១) បង្គាប់ដល់អង្គភាពបកប្រែភាសា ឱ្យផ្តល់នូវការបកប្រែដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ ជាបញ្ហាបន្ទាន់បំផុត និង (២) ផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍របស់ភាគី ប្រឆាំងដីកាដំណោះស្រាយ ដោយរង់ចាំទទួលបាននូវឯកសារបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិសិន[12]។

7. ដោយអនុលោមតាមវិធាន ៣៩(២) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារ អង្គបុរេជំនុំជម្រះអាចកំណត់ និង/ឬពន្យារកាលបរិច្ឆេទកំណត់ណាមួយ សម្រាប់ការដាក់ឯកសារ ទាក់ទងបណ្តឹងឧទ្ធរណ៍ ដោយគិតពិចារណាដល់កាលៈទេសៈនៃសំណុំរឿង។

8. អង្គបុរេជំនុំជម្រះពិចារណា ដោយមានការសោកស្តាយ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា ដែលមានទំហំ និងភាពស្មុគស្មាញ ព្រមទាំងវិសាលភាព និងសារៈសំខាន់នៃបញ្ហាអង្គហេតុនិងអង្គច្បាប់ ដែលបានលើកឡើងក្នុងនោះផង តែមួយភាសានៃភាសាការងាររបស់ អ.វ.ត.ក ព្រមទាំងភាពខុសឆ្គងដែលអាចមើលឃើញយ៉ាងងាយនៅក្នុងឯកសារបកប្រែជាភាសាអង់គ្លេស របស់ដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ។

9. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា អង្គភាពបកប្រែភាសា បានចាប់ផ្តើមរួចហើយ នូវការត្រួតពិនិត្យឡើងវិញតាមការស្នើសុំ ហើយបានជូនដំណឹងដល់អង្គជំនុំជម្រះថា ឯកសារបកប្រែជាភាសា

[11] សំណុំរឿង ០០៤ សារអេឡិចត្រូនិករបស់ ក.ស.ព ទាក់ទងការកែតម្រូវឯកសារបកប្រែ ដីកាសម្រេចលើកលែងការចោទប្រកាន់ សំណុំរឿង ០០៤ ឯកសារ D381 ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៩ ឯកសារ D382/6 ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។
[12] សំណុំរឿង ០០៤ សំណើសុំផ្អាក។

អង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ នឹងត្រូវដាក់ជូននៅមុនសប្តាហ៍ទីបី ខែតុលា ឆ្នាំ២០១៩។

10. អង្គបុរេជំនុំជម្រះសូមរំឭកអំពីកាតព្វកិច្ចរបស់អង្គជំនុំជម្រះ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង និងមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងយល់ឃើញថា ជាការសមហេតុផលក្នុងការផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍របស់ភាគីនានា ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ រហូតដល់ពេលដែលអង្គភាពបកប្រែភាសា បញ្ចប់ដោយពេញលេញនូវការត្រួតពិនិត្យឡើងវិញ និងដាក់នូវឯកសារបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ។ មិនមានការអនុញ្ញាតឲ្យពន្យារពេលបន្ថែមពីលើនេះទៀតឡើយ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**ទទួលយក ផ្នែកខ្លះនៃ**សំណើសុំផ្អាក។

**បង្គាប់ឲ្យ** ផ្អាកកាលបរិច្ឆេទកំណត់ សម្រាប់ភាគីក្នុងការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ រហូតដល់ពេលមានការជូនដំណឹងពីអង្គភាពបកប្រែភាសាអំពីឯកសារបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ។

**បង្គាប់ដល់** អង្គភាពបកប្រែភាសា ឲ្យបញ្ចប់ដោយពេញលេញនូវការត្រួតពិនិត្យឡើងវិញ និងដាក់នូវឯកសារបកប្រែជាភាសាអង់គ្លេសដែលត្រឹមត្រូវ សម្រាប់ដីកាសម្រេចលើកលែងការចោទប្រកាន់ របស់សហចៅក្រមស៊ើបអង្កេតជាតិ ឲ្យបានមុនសប្តាហ៍ទីបីនៃខែតុលា។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៩**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **នី ថុល** **Kang Jin BAIK** **ហួត វុទ្ធី**